Khmer | ភាសាខ្មែរ

# ការបង្កើតទម្រង់ផ្លូវការបន្ទាប់ទៀតនៃយុទ្ធសាស្ត្រជាតិស្ដីពីពិការភាព

## របាយការណ៍ស្ដីពីអ្វីដែលសហគមន៍បានប្រាប់យើង

# របៀបប្រើរបាយការណ៍នេះ




Social Deck បានសរសេររបាយការណ៍នេះសម្រាប់រដ្ឋាភិបាលអូស្ត្រាលី។ នៅពេលណាអ្នកឃើញពាក្យ ‘យើង’ នោះមានន័យថា រដ្ឋាភិបាលអូស្ត្រាលី។




យើងបានសរសេររបាយការណ៍នេះ ក្នុងលំនាំមួយដែលងាយស្រួលអាន។

យើងប្រើរូបភាព ដើម្បីពន្យល់ពីគំនិតមួយចំនួន។




យើងបានសរសេរពាក្យខ្លះជាអក្សរ**ដិតក្រាស់**។

យើងពន្យល់ពីអត្ថន័យនៃពាក្យទាំងនេះ។

មានបញ្ជីពាក្យទាំងនេះនៅទំព័រ 27។



របាយការណ៍ងាយស្រួលអាននេះ គឺជាសេចក្ដីសង្ខេបនៃរបាយការណ៍មួយទៀត។




អ្នកអាចរកឃើញរបាយការណ៍ផ្សេងទៀត នៅលើវ៉ិបសៃថ៍របស់យើង នៅ **www.engage.dss.gov.au/a-new-national-disability-strategy-for-beyond-2020**



អ្នកអាចស្នើសុំជំនួយដើម្បីអានរបាយការណ៍នេះ។

មិត្តភក្តិ សមាជិកគ្រួសារ ឬអ្នកជួយគាំទ្រអាចជួយអ្នកបាន។

# តើមានអ្វីខ្លះនៅក្នុងរបាយការណ៍នេះ ?


| | |
|---|---|
| តើយុទ្ធសាស្ត្រជាតិស្តីពីពិការភាពគឺជាអ្វី? | 4 |
| យុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មី | 7 |
| ការនិយាយជាមួយសហគមន៍អំពីយុទ្ធសាស្ត្រ | 9 |
| អ្វីដែលសហគមន៍បានប្រាប់យើង | 12 |
| ចក្ខុវិស័យរបស់យើងសម្រាប់យុទ្ធសាស្ត្រថ្មី | 22 |
| តើមានអ្វីកើតឡើងបន្ទាប់ទៀត ? | 25 |
| បញ្ជីពាក្យ | 27 |
| ទាក់ទងមកយើង | 30 |

# តើយុទ្ធសាស្ត្រជាតិស្តីពីពិការភាពគឺជាអ្វី?




*យុទ្ធសាស្ត្រជាតិស្តីពីពិការភាព ឆ្នាំ 2010-2020*

គឺជាផែនការមួយដើម្បីកែលម្អ

ជីវិតរបស់ជនពិការ។

នៅក្នុងឯកសារនេះយើងហៅថា ‘យុទ្ធសាស្ត្រ’។



យុទ្ធសាស្ត្រនេះនិយាយអំពីអ្វីដែលយើងអាចធ្វើបាន

ដើម្បីធ្វើឱ្យប្រទេសអូស្ត្រាលីកាន់តែមាន៖

- **ការរួមបញ្ចូលគ្នា**
- **ការចូលប្រើប្រាស់បាន។**



ប្រសិនបើមានអ្វីដែលអាចរួមបញ្ចូលគ្នាបាន

នោះមនុស្សគ្រប់គ្នាអាចចូលរួមបាន។



ប្រសិនបើមានអ្វីអាចចូលប្រើប្រាស់បាន

នោះមនុស្សគ្រប់គ្នាអាចប្រើប្រាស់វាបាន។ នេះអាចជា៖

- ទីកន្លែង ឬអគារ
- ការដឹកជញ្ជូន
- សេវាកម្ម
- ព័ត៌មាន
- វ៉ិបសៃថ៍



យុទ្ធសាស្ត្រនេះពន្យល់ពីរបៀបដែលជនពិការគួរតែ៖

- ត្រូវបានគេប្រព្រឹត្តមកលើរូបខ្លួន ដូចគ្នានឹងមនុស្សគ្រប់រូប
- ត្រូវបានគេដាក់បញ្ចូលក្នុងសហគមន៍របស់យើង។




យុទ្ធសាស្ត្រ គឺផ្អែកលើគំនិតដែលមាននៅក្នុង *អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ* (អនុសញ្ញាអង្គការសហប្រជាជាតិ)។




អនុសញ្ញាអង្គការសហប្រជាជាតិ គឺជាកិច្ចព្រមព្រៀងអន្តរជាតិ។

អនុសញ្ញានេះត្រូវបានគេអនុវត្តនៅទូទាំងពិភពលោក។



អនុសញ្ញាអង្គការសហប្រជាជាតិ ចែងពីសិទ្ធិរបស់ជនពិការ។

អនុសញ្ញានេះពន្យល់ពីវិធីដែលជនពិការ គួរត្រូវបានគេគោរពដោយយុត្តិធម៌។

# យុទ្ធសាស្ត្រជាតិស្តីពីពិការភាពថ្មី



នៅឆ្នាំ 2020 យុទ្ធសាស្ត្រនេះនឹងបញ្ចប់។



រដ្ឋាភិបាលនៅទូទាំងប្រទេសអូស្ត្រាលី កំពុងធ្វើការជាមួយគ្នា

ដើម្បីបង្កើតយុទ្ធសាស្ត្រថ្មីមួយ។



យើងចង់ដឹងពីអ្វីដែលមនុស្សគិតថា

គួរតែមានដាក់នៅក្នុងយុទ្ធសាស្ត្រថ្មីនេះ។

យើងបានសួរមនុស្សមួយចំនួនអំពីអ្វីដែលពួកគេបានគិត៖



- នៅក្នុងការស្ទង់មតិ



- នៅសិក្ខាសាលាសហគមន៍



- តាមរយៈការនិយាយជាមួយពួកគេផ្ទាល់



- តាមរយៈការនិយាយជាមួយពួកគេតាមអនឡាញ



របាយការណ៍នេះ គឺនិយាយអំពីអ្វីដែលប្រជាជននៅក្នុងសហគមន៍បានប្រាប់យើង។

# ការនិយាយជាមួយសហគមន៍អំពីយុទ្ធសាស្ត្រ




ជាការមានសារៈសំខាន់ខ្លាំងណាស់ក្នុងការនិយាយទៅកាន់សហគមន៍អំពីផែនការដែលយើងរៀបចំសម្រាប់

យុទ្ធសាស្ត្រថ្មី។

យើងបាននិយាយទៅកាន់៖



- ជនពិការ



- គ្រួសារ



- អ្នកថែទាំ



- **អ្នកតស៊ូមតិ** - មនុស្សដែលនិយាយគាំទ្រជនពិការ



- អ្នកផ្តល់សេវាកម្ម



- **អ្នកសិក្សាថ្នាក់ខ្ពស់** - មនុស្សដែលបង្រៀននៅវិទ្យាល័យ ឬសាកលវិទ្យាល័យ។



យើងបានស្តាប់ឮពីប្រជាជននៅក្នុងសហគមន៍តាមវិធីផ្សេងៗគ្នា។




មនុស្សចំនួន 2649 នាក់បានឆ្លើយសំណួរទាំងនោះ នៅក្នុងការស្ទង់មតិ។




មានមនុស្ស 599 នាក់បានចូលរួមក្នុងសិក្ខាសាលាសហគមន៍។




យើងបាននិយាយទៅកាន់ប្រជាជនជាជនជាតិដើម

និងប្រជាជនរស់នៅលើកោះ Torres Strait ចំនួន 474 នាក់។




យើងបាននិយាយទល់មុខគ្នាជាមួយ៖

- អង្គការចំនួន 15 ដោយផ្ទាល់
- មនុស្ស 14 នាក់ នៅតាមអនឡាញ។

# អ្វីដែលសហគមន៍បានប្រាប់យើង



ប្រជាជនបានផ្តល់ឱ្យយើងនូវគំនិតសំខាន់ៗជាច្រើនដើម្បី គិតអំពីយុទ្ធសាស្ត្រថ្មី។



ពួកគេបាននិយាយថា ជនពិការចាំបាច់ត្រូវបានគេរាប់បញ្ចូល រាល់ពេលធ្វើការសម្រេចចិត្តអំពីពួកគេ។

នេះរួមមាន៖




- អ្វីដែលមាននៅក្នុងយុទ្ធសាស្ត្រថ្មី




- របៀបដែលយុទ្ធសាស្ត្រថ្មីដំណើរការ។



ពួកគេនិយាយថា ជាការសំខាន់ខ្លាំងណាស់ដែលរដ្ឋាភិបាលបំពេញនូវអ្វីដែលយុទ្ធសាស្ត្រថ្មីចែង។



ប្រជាជនបាននិយាយថា គួរតែមានក្រុមមួយដែលត្រួតពិនិត្យមើលពីរបៀបដែលរដ្ឋាភិបាលកំពុងដំណើរការយុទ្ធសាស្ត្រថ្មីនេះ។




ពួកគេក៏បាននិយាយផងដែរថា គួរតែមានរបាយការណ៍មួយជារៀងរាល់ឆ្នាំ អំពីរបៀបដែលយុទ្ធសាស្ត្រថ្មីនេះកំពុងដំណើរការ។

## តើមានអ្វីខ្លះត្រូវបានកែលម្អសម្រាប់ជនពិការ?




ប្រជាជននៅក្នុងសហគមន៍បានប្រាប់យើងថា មានកិច្ចការមួយចំនួន ត្រូវបានកែលម្អក្នុងអំឡុងពេល 10 ឆ្នាំចុងក្រោយនេះ។

ប្រជាជនបាននិយាយថា៖



- ពួកគេអាចទទួលបានសេវាកម្ម និងការគាំទ្រ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេបានប្រសើរជាងមុន



- របៀបដែលសហគមន៍គិត និងមានអារម្មណ៍អំពីជនពិការ ត្រូវបានកែលម្អ




- ជនពិការកាន់តែច្រើនត្រូវបានគេដាក់បង្ហាញ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ



- មានជនពិការកាន់តែច្រើនស្ថិតនៅក្នុងការងារសំខាន់ៗ




- មានសហគមន៍កាន់តែច្រើនអាចចូលប្រើប្រាស់បាន។

**តើជនពិការនៅតែប្រឈមនឹងបញ្ហាអ្វីខ្លះ?**



ជនពិការនៅតែប្រឈមមុខនឹងរបាំង

និងឧបសគ្គនៅក្នុងសហគមន៍របស់យើង។




មានប្រជាជនជាង 80% ដែលបានចូលរួមនៅក្នុងការស្ទង់មតិ

បាននិយាយថា មនុស្សមិនមានពិការភាព

មិនដឹងពីរបៀបបង្ហាញឥរិយាបថទៅកាន់ជនពិការទេ។




31% នៃជនពិការដែលបានចូលរួមក្នុងការស្ទង់មតិបាននិយាយថា
**ការរើសអើង** រឹតកាន់តែអាក្រក់
ក្នុងរយៈពេល 5 ឆ្នាំចុងក្រោយនេះ។



ការរើសអើង កើតមាននៅពេលណាអ្នកត្រូវបានគេប្រព្រឹត្ត
មកលើរូបអ្នកដោយអយុត្តិធម៌ ដោយសារតែពិការភាពរបស់អ្នក។




34% នៃជនពិការដែលបានចូលរួមក្នុងការស្ទង់មតិបាននិយាយអំពី
បទពិសោធន៍នៃ**អំពើហឹង្សា ការរំលោភបំពាន ការធ្វេសប្រហែស**
និង**ការកេងប្រវ័ញ្ច** គឺរឹតកាន់តែអាក្រក់ក្នុងរយៈពេល 5 ឆ្នាំកន្លងមកនេះ។



អំពើហឹង្សាកើតមាន នៅពេលនរណាម្នាក់កំពុងធ្វើឱ្យអ្នកឈឺចាប់
ខាងរាងកាយ។



ការរំលោភបំពានកើតមាន
នៅពេលណានរណាម្នាក់កំពុងប្រព្រឹត្តមកលើរូបអ្នកយ៉ាងធ្ងន់ធ្ងរ។



ការធ្វេសប្រហែសកើតមាន នៅពេលនរណាម្នាក់មិនជួយអ្នក

តាមវិធីដែលពួកគេត្រូវបានសន្មត់ថានឹងជួយអ្នក។



ការកេងប្រវ័ញ្ចកើតមាន នៅពេលនរណាម្នាក់

ទាញយកផលប្រយោជន៍ពីអ្នក។




72% នៃប្រជាជនដែលបានចូលរួមក្នុងការស្ទង់មតិបាននិយាយថា

មានការពិបាកក្នុងការស្វែងរកព័ត៌មានអំពីសេវាកម្មពិការភាព។




60% នៃប្រជាជនដែលបានចូលរួមក្នុងការស្ទង់មតិបាននិយាយថា

មានការពិបាកក្នុងការស្វែងរកព័ត៌មានអំពីសិទ្ធិរបស់ជនពិការ។




យើងក៏បានរកឃើញដែរថា ប្រហែលជា 50% នៃជនពិការ

មិនចូលរួមក្នុងសកម្មភាពសហគមន៍ជាញឹកញាប់ទេ។



សកម្មភាពសហគមន៍ អាចរួមមាន៖

- ការទៅផ្សារទិញឥវ៉ាន់
- ការទៅមើលកុន
- ការទៅចូលរួមក្នុងព្រឹត្តិការណ៍កីឡានានា ដូចជាបាល់ទាត់។



មូលហេតុទូទៅបំផុតដែលជនពិការមិនចូលរួម

គឺដោយសារតែពួកគេមិនមានប្រាក់គ្រប់គ្រាន់។

ជនពិការបាននិយាយថា បញ្ហាប្រឈមធំបំផុតដែលពួកគេជួបប្រទះគឺ៖



- ការស្វែងរកការងារ និងការរក្សាការងារ



- ការមានលុយគ្រប់គ្រាន់។



ជនពិការក៏បានប្រាប់យើងដែរអំពីបញ្ហាប្រឈមផ្សេងទៀត
ដែលរារាំងពួកគេមិនឱ្យរស់នៅក្នុងជីវិតដែលពួកគេចង់បាន។

បញ្ហាប្រឈមទាំងនេះ រួមមាន៖




- ប្រជាជនមិនគាំទ្រសិទ្ធិរបស់ពួកគេ



- មិនអាចធ្វើកិច្ចការដោយខ្លួនឯង



- មិនមានសុខភាព និងសុខុមាលភាពល្អ



- មិនរាប់បញ្ចូលជនពិការ
  នៅពេលមានការផ្លាស់ប្តូរដែលប៉ះពាល់ដល់ពួកគេ



- មិនមានមនុស្សដែលអាចយល់ថាក្រុមជនពិការផ្សេងៗគ្នា
  អាចមានបញ្ហាប្រឈមផ្សេងៗគ្នា។

## ក្រុមនៅក្នុងសហគមន៍របស់យើង



មានក្រុមជាច្រើននៅក្នុងសហគមន៍របស់យើង

ដែលប្រឈមនឹងបញ្ហា និងឧបសគ្គបន្ថែម។

ក្រុមផ្សេងៗគ្នាទាំងនេះ រួមមាន៖



- ប្រជាជនដែលរស់នៅតាមទីជនបទ ហើយនៅឆ្ងាយពីទីប្រជុំជន និងទីក្រុង



- ប្រជាជនជាជនជាតិដើម និងប្រជាជនរស់នៅលើកោះ Torres Strait



- កុមារ និងមនុស្សវ័យក្មេង




- មនុស្សដែលមានអាយុលើសពី 65 ឆ្នាំ



- ស្ត្រី



- ស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទដូចគ្នា មនុស្សដែលមានភេទពីរ អ្នកប្តូរភេទ អន្តរភេទ ឬមនុស្សដែលរួមប្រតិព័ទ្ធនឹងមនុស្សដូចគ្នា (LGBTIQ+)



- មនុស្សដែលមិនមានប្រាក់ច្រើន



- មនុស្សមកពី**វប្បធម៌**ខុសគ្នា។




វប្បធម៌របស់អ្នកគឺជាពូជសាសន៍របស់អ្នក ភាសាដែលអ្នកនិយាយ ឬរបៀបដែលអ្នករស់នៅក្នុងជីវិតរបស់អ្នក ដោយសារតែកន្លែងដែលអ្នក និងគ្រួសាររបស់អ្នកបានកើតមក។

# ចក្ខុវិស័យរបស់យើងសម្រាប់យុទ្ធសាស្ត្រថ្មី




**ចក្ខុវិស័យ**របស់យើង គឺជាអ្វីដែលយើងចង់បានយុទ្ធសាស្ត្រថ្មីដើម្បីជួយ ធ្វើឱ្យអនាគតបានល្អប្រសើរឡើង។




ប្រជាជនបានប្រាប់យើងអំពីចក្ខុវិស័យរបស់ពួកគេ សម្រាប់យុទ្ធសាស្ត្រថ្មី។

ពួកគេបាននិយាយថា ពួកគេចង់ឃើញ៖




- ប្រទេសអូស្ត្រាលីមានឈ្មោះក្នុងបញ្ជី ថាជាប្រទេសដែលផ្តល់ការគាំទ្រល្អដល់ជនពិការ



- គោរពសិទ្ធិមនុស្សទាំងអស់




- ច្បាប់ថ្មីដើម្បីគាំទ្រសិទ្ធិរបស់ជនពិការ



- ការងារកាន់តែច្រើនសម្រាប់ជនពិការ



- ជនពិការអាចចូលប្រើប្រាស់ផ្ទះសំបែងបានកាន់តែច្រើនឡើង



- មនុស្សគ្រប់គ្នាអាចចូលប្រាស់សហគមន៍នានាបាន



- ជីវិតប្រសើរសម្រាប់ជនពិការទាំងអស់



- បង្កើត**គោលនយោបាយ**ថ្មីៗ ដោយទាក់ទិនជាមួយជនពិការ។




គោលនយោបាយ គឺជាផែនការរបស់រដ្ឋាភិបាល សម្រាប់ពេលអនាគត។

# តើមានអ្វីកើតឡើងបន្ទាប់ទៀត ?



យើងបានស្ដាប់នូវអ្វីគ្រប់យ៉ាងដែលមនុស្សបានប្រាប់យើង ដែលមានសារៈសំខាន់សម្រាប់ពួកគេ។




ឥឡូវនេះ យើងនឹងចាប់ផ្ដើមបង្កើតយុទ្ធសាស្ត្រថ្មី។

ខណៈពេលដែលយើងកំពុងបង្កើតយុទ្ធសាស្ត្រថ្មី យើងនឹង៖



- ផ្ដល់ឱកាសឱ្យមនុស្សគ្រប់រូបប្រាប់យើង ពីអ្វីដែលពួកគេគិតអំពីរឿងទាំងឡាយយើងចង់ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រ




- គិតឱ្យបានច្រើនជាងមុនអំពីសិទ្ធិរបស់ជនពិការ ដើម្បីធ្វើការ និងរបៀបដាក់បញ្ចូលសិទ្ធិនេះទៅក្នុងយុទ្ធសាស្ត្រ



- បង្ហាញវិធីដែលរដ្ឋាភិបាលអាចជួយដល់ជនពិការ ដែលមិនចូលរួមក្នុងគម្រោងធានារ៉ាប់រងសម្រាប់ជនពិការថ្នាក់ជាតិ (NDIS)



- ពិនិត្យមើលរបៀបដែលរដ្ឋាភិបាលអាចគាំទ្រដល់ជនពិការ ដើម្បីប្រើប្រាស់បច្ចេកវិទ្យាថ្មី



- បង្ហាញរដ្ឋាភិបាលអំពីរបៀបដែលជនពិការអាចចូលប្រើប្រាស់សហគមន៍បានកាន់តែច្រើនឡើង



- ពិនិត្យមើលពីរបៀបដែលក្រុមជនពិការផ្សេងៗគ្នាត្រូវបានគាំទ្រ និងវិធីដែលរដ្ឋាភិបាលអាចជួយពួកគេបាន




- គិតអំពីរបៀបដែលរដ្ឋាភិបាលនឹងបង្ហាញថា ពួកគេកំពុងធ្វើអ្វីដែលយុទ្ធសាស្ត្រចែងមក។

# បញ្ជីពាក្យ



**ការរំលោភបំពាន**

ពេលណានរណាម្នាក់កំពុងធ្វើបាបអ្នកយ៉ាងធ្ងន់ធ្ងរ។



**អ្នកសិក្សាថ្នាក់ខ្ពស់**

បុគ្គលដែលបង្រៀននៅវិទ្យាល័យ ឬសាកលវិទ្យាល័យ។



**អាចចូលប្រើប្រាស់បាន**

ប្រសិនបើមានអ្វីមួយអាចចូលប្រើប្រាស់បាន នោះមនុស្សគ្រប់គ្នាអាចប្រើប្រាស់វាបាន។ នេះអាចជា៖

- ទីកន្លែង ឬអគារ
- ការដឹកជញ្ជូន
- សេវាកម្ម
- ព័ត៌មាន
- វ៉ិបសៃថ៍



**អ្នកគាំទ្រមតិ**

មនុស្សម្នាក់ដែលគាំទ្រអ្នក។ ពួកគេជួយអ្នកដើម្បីបញ្ចេញមតិរបស់អ្នក។ ពួកគេក៏អាចផ្តល់ឱ្យអ្នកនូវព័ត៌មាន និងដំបូន្មានផងដែរ។



**វប្បធម៌**

ពូជសាសន៍របស់អ្នក ភាសាដែលអ្នកនិយាយ ឬរបៀបដែលអ្នករស់នៅក្នុងជីវិតរបស់អ្នក ដោយសារតែកន្លែងដែលអ្នក និងគ្រួសាររបស់អ្នកបានកើតមក។



**ការរើសអើង**

ការរើសអើង កើតមាននៅពេលណាអ្នកត្រូវបានគេប្រព្រឹត្តមកលើរូបអ្នកដោយអយុត្តិធម៌ ដោយសារតែពិការភាពរបស់អ្នក។



**ការកេងប្រវ័ញ្ច**

ពេលណានរណាម្នាក់ ទាញយកផលប្រយោជន៍ពីអ្នក។



## ការបញ្ចូលគ្នា

ប្រសិនបើមានអ្វីដែលដាក់រួមបញ្ចូលគ្នា

នោះមនុស្សគ្រប់គ្នាអាចចូលរួមបាន។



## ការធ្វេសប្រហែស

ពេលណានរណាម្នាក់មិនជួយអ្នក

តាមវិធីដែលពួកគត្រូវបានសន្មត់ថានឹងជួយអ្នក។




## គោលនយោបាយ

ផែនការរបស់រដ្ឋាភិបាលសម្រាប់ពេលអនាគត។



## អំពើហឹង្សា

ពេលណានរណាម្នាក់កំពុងធ្វើឱ្យអ្នកឈឺចាប់ខាងរាងកាយ។




## ចក្ខុវិស័យ

**ចក្ខុវិស័យ**របស់យើង គឺជាអ្វីដែលយើងចង់បានយុទ្ធសាស្ត្រថ្មីដើម្បីជួយ

ធ្វើឱ្យអនាគតបានល្អប្រសើរឡើង។

# ទាក់ទងមកយើង

**1800 334 505**

អ្នកក៏អាចទូរស័ព្ទទៅសេវាកម្មបញ្ជូនបន្តថ្នាក់ជាតិផងដែរ។

អ្នកប្រើប្រាស់ TTY៖ **1800 555 677**

ទូរស័ព្ទ៖ **13 36 77**

**disabilityreform@dss.gov.au**

**www.engage.dss.gov.au**

ក្រុមអ្នកចូលប្រើប្រាស់ព័ត៌មាន បានបង្កើតសន្លឹកព័ត៌មានងាយស្រួលអាននេះ ដោយប្រើរូបស្តុកថត និងរូបភាពនានាធ្វើតាមតម្រូវការ។ រូបភាពទាំងនេះមិនអាចយកប្រើឡើងវិញ ដោយគ្មានការអនុញ្ញាតឡើយ។ សម្រាប់សំណួរណាមួយអំពីរូបភាព សូមចូលមើលនៅតាមវ៉ិបសៃថ៍ **www.informationaccessgroup.com**។ សូមសម្រង់លេខការងារ 3319។